**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ELECTRICITE DU CAMBODGE

**អគ្គិសនីកម្ពុជា**

លេខ: ៩៥៩០ អដ៧.អក.២អ៨

ថ្ងៃ អង្គារ ០៩កើត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ២០២០

## សេចក្តីជូនដំណឹង

**អគ្គិសនីកម្ពុជា** មានកិត្តិយសសូមជម្រាបជូនសាធារណជនឲ្យបានជ្រាបថា៖ គោលនយោបាយវិស័យថាមពលរបស់រាជរដ្ឋាភិបាលកម្ពុជា អាណត្តិទី៦ នៃរដ្ឋសភានេះ **រាជរដ្ឋាភិបាលកម្ពុជា** មានមហិច្ឆតាគ្រប់គ្រង និងជំរុញការអភិវឌ្ឍវិស័យថាមពលអគ្គិសនីដើម្បី "ឈានទៅសម្រេចឲ្យបានការផ្គត់ផ្គង់ថាមពលអគ្គិសនីមួយគ្រប់គ្រាន់ មានចីរភាព អាចទុកចិត្តបាន មានគុណភាព និងមានថ្លៃសមរម្យសម្រាប់អ្នកប្រើប្រាស់គ្រប់ប្រភេទ នៅគ្រប់ទីកន្លែង ទូទាំងព្រះរាជាណាចក្រកម្ពុជា"។ **អគ្គិសនីកម្ពុជា** បន្តផ្តល់ថវិកាជាអំណោយដល់នាយកដ្ឋានមូលនិធិអគ្គិសនីការូបនីយកម្មជនបទនៃអគ្គិសនីកម្ពុជា (ហៅកាត់ថា "ម.អ.ជ.") ដើម្បីបន្តអនុវត្ត "**កម្មវិធីជួយទុនសម្រាប់ពង្រីក និងកែលម្អការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ**"។ កម្មវិធីនេះ ជាកម្មវិធីអនុវត្តពីឆ្នាំ២០១៣ និងបន្តអនុវត្តក្នុងឆ្នាំ២០២១។ គោលបំណងនៃកម្មវិធីនេះ គឺជួយសម្រួលដល់សេវាករអគ្គិសនីនៅតំបន់ជនបទដែលមានអាជ្ញាបណ្ណស្របច្បាប់មានទុន សម្រាប់វិនិយោគពង្រីក និងកែលម្អការផ្គត់ផ្គង់អគ្គិសនីឲ្យពេញដែនអាជ្ញាបណ្ណរបស់ខ្លួន ដើម្បីឲ្យប្រជាពលរដ្ឋជនបទគ្រប់គ្រួសារអាចភ្ជាប់ចរន្តប្រើប្រាស់តាមលទ្ធភាពរបស់ខ្លួន។ ក្រោមកម្មវិធីនេះ ម.អ.ជ. នឹងផ្តល់ប្រាក់កម្ចីដោយពុំយកការប្រាក់សម្រាប់វិនិយោគលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអគ្គិសនីនៅតំបន់ជនបទ ដែលមានដង់ស៊ីតេប្រជាពលរដ្ឋរស់នៅមធ្យម និង ម.អ.ជ. នឹងផ្តល់ប្រាក់ឧបត្ថម្ភធនមួយផ្នែកបន្ថែមពីលើប្រាក់កម្ចីដោយពុំយកការប្រាក់សម្រាប់វិនិយោគលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ ដែលមានដង់ស៊ីតេប្រជាពលរដ្ឋរស់នៅទាប។ សេវាករត្រូវសងប្រាក់កម្ចីរំលស់ប្រចាំខែមក ម.អ.ជ. វិញ ក្នុងរយៈពេលយ៉ាងយូរ ៨ឆ្នាំ ឬមិនលើសពីអាណត្តិអាជ្ញាបណ្ណ។

សេវាករត្រូវដាក់ពាក្យ មក ម.អ.ជ. សម្រាប់ការស្នើសុំជួយទុនសម្រាប់ពង្រីក និងកែលម្អការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ តាមគំរូពាក្យដែលមានស្រាប់នៅ ម.អ.ជ.។ ប្រសិនបើ ម.អ.ជ. និងអាជ្ញាធរអគ្គិសនីកម្ពុជាយល់ព្រមលើសំណើសុំ នោះកិច្ចសន្យាជួយទុននឹងត្រូវចុះហត្ថលេខារវាង ម.អ.ជ. និងសេវាករ។ សេវាករត្រូវសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់អគ្គិសនីក្រោមកិច្ចសន្យានេះ ដោយធនធានខ្លួនឯងជាមុន។ ម.អ.ជ. នឹងពិនិត្យទូទាត់ថវិកាជួយទុនឲ្យទៅសេវាករ ស្របតាមវឌ្ឍនភាពហេដ្ឋារចនាសម្ព័ន្ធអគ្គិសនីដែលបានសាងសង់រួច។

ព័ត៌មានបន្ថែមសូមទំនាក់ទំនងមកលោក ជុំ ចាន់តារា ទូរស័ព្ទលេខ 015 776-770 / 011 244-246 ឬលោក ថាច់ កៀងមុនី ទូរស័ព្ទលេខ 016 988-685 ឬទាក់ទងមក ម.អ.ជ. តាមទូរស័ព្ទលេខ 089 776-770 / 023 997-600 ឬទូរសារលេខ 023 997-601 ឬអញ្ជើញមកទំនាក់ទំនងនៅនាយកដ្ឋាន ម.អ.ជ. មានទីតាំងនៅអាគារលេខ២០៥ ផ្លូវជាតិលេខ៥ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។

**រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**

**អគ្គនាយកអគ្គិសនីកម្ពុជា**

ELECTRICITE DU CAMBODGE

**កែវ រតនៈ**

ចម្លងជូន៖
- អាជ្ញាធរអគ្គិសនីកម្ពុជា
- អគ្គនាយករងអគ្គិសនីកម្ពុជា

  ដើម្បី "ជូនជ្រាប"
- ឯកសារ-កាលប្បវត្តិ